**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ០៤ សរ

# សារាចរ
## ស្តីពី
## ការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា

ទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ត្រូវបានរៀបចំស្របតាមគោលនយោបាយជាតិសម្រាប់មនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។ ការប្រារព្ធទិវានេះ មានគោលបំណងលើកកម្ពស់កិច្ចគាំពារដ៏មានប្រសិទ្ធភាព សំដៅលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ឱ្យកាន់តែប្រសើរឡើង ហើយទិវានេះក៏បង្ហាញឱ្យឃើញអំពីតួនាទីដ៏សំខាន់របស់មនុស្សចាស់ បុព្វការីជន ដែលបានបង្កើតធនធានដ៏មានសារៈប្រយោជន៍ ព្រមទាំងផ្តល់នូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍យ៉ាងច្រើនឥតគណនាសម្រាប់មនុស្សជំនាន់ក្រោយ។ ក្នុងគោលបំណងយកចិត្តទុកដាក់ខ្ពស់ចំពោះមនុស្សចាស់កម្ពុជា រាជរដ្ឋាភិបាលបានបង្កើតឱ្យមានគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ដើម្បីអនុវត្តនូវតួនាទី និងភារកិច្ចដែលមានជាអាទិ៍ រៀបចំគោលនយោបាយជាតិ ដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ និងរៀបចំទិវាមនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី០១ ខែតុលា ជារៀងរាល់ឆ្នាំ រួមជាមួយទិវាមនុស្សចាស់អន្តរជាតិ។

រាជរដ្ឋាភិបាលចាត់ទុកទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ជាទិវាបុណ្យរម្លឹកដល់គុណូបការៈរបស់មនុស្សចាស់កម្ពុជា បុព្វការីជន ជីដូន ជីតា ឪពុក ម្តាយ អ៊ុំ ពូ មីង ដែលបានកសាង និងបន្សល់ទុកនូវកេរមរតកដ៏ថ្លៃថ្លាសម្រាប់កូនចៅជំនាន់នេះ និងជំនាន់ក្រោយៗទៀត។ ដើម្បីរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ឱ្យបានទូលំទូលាយ និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប បានយល់ដឹងកាន់តែច្បាស់អំពីអត្ថន័យនៃទិវានេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១- ប្រធានបទនៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ត្រូវបានកំណត់ថា "**សមាគមមនុស្សចាស់ជាយន្តការដ៏សំខាន់ ជួយអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិ**"។

២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ត្រូវសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិ ដែលពាក់ព័ន្ធដើម្បីចាត់តាំងមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ឱ្យបានអធិកអធម។

៣- រាជធានី ខេត្ត ត្រូវរៀបចំមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៤ ដោយបង្កលក្ខណៈឱ្យមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃ បព្វជិត លោកយាយ លោកតា ព្រមទាំងប្រជាជនគ្រប់វ័យបានចូលរួម ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែទូលំទូលាយអំពីសារៈសំខាន់នៃគោលនយោបាយជាតិ ចំពោះមនុស្សចាស់កម្ពុជា។

៤- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ សូមបន្តជួយគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍សមាគមមនុស្សចាស់ដែលមានស្រាប់ និងបង្កើតបន្ថែមទៀត នៅតាមសហគមន៍មូលដ្ឋាននៅគ្រប់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កើនការយកចិត្តទុកដាក់អនុវត្តតាមការណែនាំ និងបង្កើតឱ្យមានសមាគមមនុស្សចាស់ក្នុងមូលដ្ឋានគ្រប់ឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើនស្មារតីសាមគ្គីភាពជួយគ្នាទៅវិញទៅមក រវាងមនុស្សចាស់ទូទៅ ជាពិសេសយកចិត្តទុកដាក់ជួយជនចាស់ជរា ពិការ ក្រីក្រទុរគត។

៥- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំកម្មវិធីចុះសំណេះសំណាលជាមួយមនុស្សចាស់ នៅតាមមូលដ្ឋាន វត្តអារាម វិហារសាសនានានា ដោយនាំយកជំនួយឧបត្ថម្ភតាមសទ្ធាជ្រះថ្លា ជួយដល់មនុស្សចាស់ជរា ពិការ ក្រីក្រទុរគត។

៦- ក្រសួងធម្មការ និងសាសនា ត្រូវធ្វើការណែនាំនិងចលនានៅតាមវត្តអារាម វិហារសាសនាទូទាំងប្រទេសតាមរយៈបព្វជិតសាសនា ដើម្បីឱ្យមានសកម្មភាពជួយឧបត្ថម្ភគាំទ្រដល់ជនចាស់ជរា ពិការ ក្រីក្រទុរគត។

៧- ក្រសួងព័ត៌មាន ត្រូវណែនាំបណ្តាញព័ត៌មានរដ្ឋ និងឯកជនទាំងអស់ ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវខ្លឹមសារនិងសកម្មភាពនៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤។

៨- គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំបដានៅតាមអង្គភាព និងទីសាធារណៈតាមខ្លឹមសារ ដូចតទៅ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា !
- អបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ០១ តុលា
- មនុស្សចាស់ជាមរតកដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និងសង្គមជាតិ
- គោរពដឹងគុណចំពោះមនុស្សចាស់ គឺជាកតញ្ញូតាធម៌ គ្រួសារមានសុភមង្គល សង្គមរីកចម្រើន
- កសាងសង្គមដែលមានការអភិវឌ្ឍសម្រាប់មនុស្សគ្រប់វ័យ
- សមាគមមនុស្សចាស់ជាយន្តការដ៏សំខាន់ ជួយអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិ។៚

៩- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវធ្វើការណែនាំអនុវត្តតាមសារាចរនេះ និងបូកសរុបលទ្ធផលការងារជូនរាជរដ្ឋាភិបាល។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ